# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គជអប
NCDD

RACHA
សម្ព័ន្ធសុខភាពកុមារ និង សុខភាពបន្តពូជ
Reproductive and Child Health Alliance

**អនុស្សរណៈយោគយល់**

**រវាង**

**លេខាធិការដ្ឋាន គ.ជ.អ.ប**

**ជាមួយនិង**

**អង្គការ សម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ (រ៉ាឆា)**

**ស្តីពី**

**ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម**
**សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**អនុស្សារណៈយោគយល់**

**រវាង**

**លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**

**និង**

**អង្គការសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ (រ៉ាឆា)**

**ស្តីពី**

**ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

## ប្រការ១៖ គណនេយ្យភាពសង្គម

ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦ រហូតដល់២០១៨ បានរៀបចំឡើងដោយមានកិច្ចសហការយ៉ាងជិតស្និតរវាងលេខាធិការដ្ឋានគ.ជ.អ.ប និងបណ្តាអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ក្រោមក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការងារគណនេយ្យភាពសង្គមគឺជាផ្នែកមួយដ៏សំខាន់នៃអភិបាលកិច្ច និងជាដំណើរការនៃការចូលរួមប្រកបដោយការស្ថាបនារវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការធ្វើសេចក្តីសម្រេចចិត្តជា សាធារណៈ និងអនុវត្តសកម្មភាពនានា។ សកម្មភាពទាំងនោះរួមបញ្ចូលនូវសកម្មភាពដែលប្រជាពលរដ្ឋ និងតំណាងប្រជាពលរដ្ឋ អាចធ្វើការផ្តល់យោបល់ត្រឡប់សម្រាប់ឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន និងអាចចូលរួមតាមដាន ត្រួតពិនិត្យ អំពីការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា មន្ត្រី និងអ្នកផ្តល់សេវាតាមរយៈសេវារដ្ឋបាលឃុំ សេវាអប់រំ (សាលាបឋមសិក្សា) និងសេវាសុខាភិបាល (មណ្ឌលសុខភាព)។

## ប្រការ២៖ គោលបំណងនៃអនុស្សារណៈយោគយល់

អនុស្សារណៈយោគយល់នេះមានគោលបំណងកំណត់អំពីការទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការ របស់ភាគីពីរគឺ លេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការរ៉ាឆា សម្រាប់ការអនុវត្តសកម្មភាពផែនការ អនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផ.អ.គ.ស)នៅក្នុងតំបន់គោលដៅដូចមានក្នុងឧបសម្ព័ន្ធទី១។

## ប្រការ៣៖ ការទទួលខុសត្រូវរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋានគ.ជ.អ.ប.ព្រមព្រៀងដូចខាងក្រោម៖

ក.ផ្តល់ការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតំបន់គោលដៅស្តីពីខ្លឹមសារនៃអនុស្សារណៈយោគយល់នេះ។

ខ.ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីជំនាញសុខាភិបាល និងមន្ត្រីជំនាញវិស័យ អប់រំនៅក្នុងតំបន់គោលដៅទាក់ទងនឹងទស្សនៈទាន ឧបករណ៍ ដំណើរការនៃការអនុវត្តផែនការសកម្មភាព គណនេយ្យភាពសង្គម ពិសេសគោលការណ៍អភិបាលកិច្ច និងខ្សែគណនេយ្យភាព ព្រមទាំងតួនាទីភារកិច្ច របស់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលចុះកិច្ចសន្យាអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម និងអង្គការសង្គមស៊ីវិល (CSO) ដែលបានទទួលកិច្ចសន្យា ពីអង្គការមិនមែនរដ្ឋាភិបាលក្នុងការលើកកម្ពស់គោលការណ៍ខាងលើ និងគាំទ្រសម្របសម្រួលការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមនៅក្នុង តំបន់គោលដៅ។

គ. គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនៅតំបន់គោលដៅដោយប្រើផ្ទាំងរូបភាពធំនៃ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4Cs) និងសៀវភៅណែនាំអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋដោយមានការណែនាំបច្ចេកទេស ឬតម្រង់ទិសពីរបៀបនៃការផលិតព័ត៌មាន ការដាក់តាំងបង្ហាញការផ្សព្វផ្សាយ និងរបៀបនៃការប្រើប្រាស់ព័ត៌មានទាំងនេះក្នុងដំណើរការ ផ.អ.គ.ស.។ ធ្វើការតាមដានជាទៀងទាត់ដើម្បីធានាថាសម្ភារៈ (I4Cs) ត្រូវបានប្រើប្រាស់ត្រឹមត្រូវ។

ឃ. សហការបណ្តុះបណ្តាលតម្រង់ទិស (ផ្នែកផ្គត់ផ្គង់) ដល់មន្ត្រីបង្គោលរបស់អង្គការដៃគូអនុវត្ត (NGOs)ស្តីពីផែនការអនុវត្តការងារគណនេយ្យភាពសង្គមដើម្បីអោយមានភាពស្របគ្នាជាមួយនឹងវគ្គបណ្តុះបណ្តាលបន្តរបស់ផ្នែកតម្រូវការដល់ដៃគូតាមបណ្តាស្រុកគោលដៅ។

ង. ផ្តល់ថវិកាគាំទ្រអោយទាន់ពេលវេលាទៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតំបន់គោលដៅដើម្បីអោយការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមស្របតាមផែនការ ក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលទាំងនោះ។

ច. ត្រួតពិនិត្យការអនុវត្តជាប្រចាំនូវការបំពេញការងារ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាតិ មន្ត្រីជំនាញផ្នែកសុខាភិបាល និងអប់រំដែលពាក់ពន្ធ័ ដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងដំណើរការដាក់ពិន្ទុដោយផ្នែកទាំងពីរ អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋ ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ត្រូវបានអនុវត្តត្រឹមត្រូវពេញលេញ និងស្របតាមផែនការអនុវត្តការងារគណនេយ្យភាពសង្គម។ ធានាថាកិច្ចខិតខំប្រឹងប្រែងសំរបសំរួលក្នុងចំណោមភាគីពាក់ព័ន្ធ ក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើងនៅគ្រប់កម្រិតទាំងអស់។

ឆ. រៀបចំ និងចែករំលែក នូវរបាយការណ៍ ស្តីពីវឌ្ឍនៈភាពនៃការអនុវត្តជាទៀងទាត់ ដូចដែលបានឯកភាពគ្នា តាមមាតិកានៃរបាយការណ៍ដែលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី២។

ជ. ផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងឡាយជាមួយ ការគាំទ្រធនធានពីអង្គការវ៉ាឆាក្នុងការអនុវត្តសកម្មភាពគណនេយ្យភាពផ្នែកផ្គត់ផ្គង់។

**ប្រការ៤៖ ការទទួលខុសត្រូវរបស់អង្គការវ៉ាឆា**

អង្គការវ៉ាឆា ព្រមព្រៀងដូចខាងក្រោម៖

ក. ផ្តល់ការណែនាំដល់បុគ្គលិក និងអង្គការសង្គមស៊ីវិលដៃគូអនុវត្តរបស់ខ្លួនទាក់ទងនឹងខ្លឹមសារនៃអនុស្សារណៈនេះ។

ខ. ធានាថាការបណ្តុះបណ្តាល ត្រូវបានផ្តល់ដល់ដៃគូ អង្គការសង្គមស៊ីវិលដែលជាដៃគូអនុវត្តរបស់ខ្លួនអំពីទស្សនទាន ឧបករណ៍ នីតិវិធី ដំណើរការ គោលការណ៍អភិបាលកិច្ចល្អ ខ្សែគណនេយ្យភាព សារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងការអនុវត្ត ផ.អ.គ.ស។

គ. ផ្តល់ថវិកាគាំទ្រអោយទាន់ពេលវេលាដល់អង្គការសង្គមស៊ីវិលដែលជាដៃគូរបស់ខ្លួនដើម្បីគាំទ្រការ អនុវត្តសកម្មភាពផ្នែកតម្រូវការក្រោមការទទួលខុសត្រូវរបស់អង្គការដៃគូនោះ។

ឃ. ត្រួតពិនិត្យ ការអនុវត្ត ជាប្រចាំរបស់ខ្លួនឬអង្គការសង្គមស៊ីវិលដែលជាដៃគូអនុវត្តរបស់ខ្លួនដើម្បីធានា ថា ផ.ស.គ.ស ត្រូវបានអនុវត្តត្រឹមត្រូវ ពេញលេញដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្រប តាមឯកសារផ.អ.គស។

ង. រៀបចំ និងចែករំលែក នូវរបាយការណ៍ស្តីពី វឌ្ឍនៈភាពនៃការអនុវត្តជាទៀងទាត់ ដូចដែលបានឯកភាពគ្នាតាមមាតិកានៃរបាយការណ៍ដែលមានភ្ជាប់ជូនជូនក្នុងឧបសម្ព័ន្ធទី២។

ច. សហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ធនធានចាំបាច់របស់អង្គការវ៉ាឆាសម្រាប់អនុវត្តសកម្មភាពគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ស្របតាមផែនការសកម្មភាពរួមដែលបានឯកភាពរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការវ៉ាឆាដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣។

## ប្រការ៥៖ ការចាត់ចែងសម្របសម្រួល

ក្នុងករណីចាំបាច់ ភាគីទាំង២ អាចរៀបចំប្រជុំសម្របសម្រួលលើការអនុវត្តគណនេយ្យភាពសង្គមជាប្រចាំ ក្នុងគោលបំណងដូចខាងក្រោម៖

- ពិនិត្យមើលអំពីភាពរីកចម្រើននៃការអនុវត្តការងារគណនេយ្យភាពសង្គម
- កំណត់ពីបញ្ហា និងស្វែងរកដំណោះស្រាយប្រកបដោយការសហការគ្នា
- ពិភាក្សា និងព្រមព្រៀងលើចំណុចកែលម្អក្នុងដំណើរការអនុវត្តដែលបានលើកឡើង ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអនុវត្តនាពេលអនាគត។
- ចូលរួមបង្កើតយុទ្ធសាស្រ្តរួមគ្នាមុនពេលបញ្ចប់អនុស្សារណៈយោគយល់គ្នានេះដើម្បីអោយគម្រោងមាននិរន្តភាព
- ការងារផ្សេងៗទៀតទាក់ទងនឹងការអនុវត្តផែនការគណនេយ្យភាពសង្គមជាទូទៅ

## ប្រការ៦៖ ការធ្វើវិសោធនកម្ម ឬការបញ្ចប់អនុស្សារណៈយោគយល់

អនុស្សារណៈយោគយល់នេះអាចនឹងត្រូវបានធ្វើវិសោធនកម្មនៅពេលណាមួយក្នុងករណីដែលមានការព្រមព្រៀងពីភាគីទាំងពីរ។ ការបញ្ចប់អនុស្សារណៈនេះ នឹងតម្រូវអោយមានការជូនដំណឹងជាលាយលក្ខណ៍ អក្សរយ៉ាងតិច ៨ សប្តាហ៍មុន និងមានការព្រមព្រៀងពីភាគីទាំងពីរទៅលើវិធានការសមស្របដើម្បីធានាឲ្យមានការ អនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅបន្ទាប់ពីការបញ្ចប់អនុស្សារណៈយោគយល់នេះ។

| | លេខាធិការដ្ឋាន គ.ជ.អ.ប ៤៥ | អង្គការរ៉ាឆា |
|---|---|---|
| ហត្ថលេខា៖ | | |
| ឈ្មោះ៖ | សក់_សេដ្ឋា | ចាន់ ឆារី |
| មុខងារ៖ | ប្រធានលេខាធិការដ្ឋានគ.ជ.អ.ប | នាយកប្រតិបត្តិ. |
| កាលបរិច្ឆេទ៖ | ០៩ មីន ២០១៦ | ០៩ មីនា ២០១៦ |

## ឧបសម្ព័ន្ធទី១៖

### ក. តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៦ ដែលកំណត់ក្នុងអនុស្សារណៈរវាង លេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការ វ៉ាឆា

| កូដ GIS | ឈ្មោះស្រុក | ចំនួនឃុំ | | ចំនួនសាលាបឋមសិក្សា | | ចំនួនមណ្ឌលសុខភាព | |
|---|---|---|---|---|---|---|---|
| | | ផ្នែកផ្គត់ផ្គង់ | ផ្នែកតម្រូវការ | ផ្នែកផ្គត់ផ្គង់ | ផ្នែកតម្រូវការ | ផ្នែកផ្គត់ផ្គង់ | ផ្នែកតម្រូវការ |
| **01** | ខេត្តបន្ទាយមានជ័យ | 20 | 20 | 120 | 107 | 21 | 21 |
| 0104 | ព្រះនេត្រព្រះ | 9 | 9 | 63 | 63 | 9 | 9 |
| 0105 | អូជ្រៅ | 7 | 7 | 24 | 22 | 6 | 6 |
| 0109 | ម៉ាឡៃ | 6 | 6 | 33 | 22 | 6 | 6 |
| **17** | ខេត្តសៀមរាប | 46 | 46 | 263 | 255 | 41 | 41 |
| 1701 | អង្គរជុំ | 7 | 7 | 36 | 35 | 7 | 6 |
| 1709 | ប្រាសាទបាគង | 8 | 8 | 41 | 41 | 7 | 7 |
| 1711 | សូត្រនិគម | 10 | 10 | 67 | 67 | 10 | 10 |
| 1712 | ស្រីស្នំ | 6 | 6 | 35 | 28 | 5 | 5 |
| 1702 | អង្គរធំ | 4 | 4 | 20 | 20 | 4 | 4 |
| 1703 | បន្ទាយស្រី | 6 | 6 | 30 | 30 | 5 | 5 |
| 1713 | ស្វាយលើ | 5 | 5 | 34 | 34 | 3 | 3 |
| **02** | ខេត្តបាត់ដំបង | 76 | 76 | 504 | 205 | 60 | 60 |
| 0201 | ថ្មគោល | 8 | 8 | 77 | 16 | 6 | 6 |
| 0202 | សង្កែ | 10 | 10 | 46 | 20 | 10 | 10 |
| 0204 | បាណន | 8 | 8 | 82 | 16 | 8 | 8 |
| 0205 | បវេល | 7 | 7 | 46 | 14 | 6 | 6 |
| 0206 | ឯកភ្នំ | 9 | 9 | 68 | 18 | 9 | 9 |
| 0208 | ម៉ោងឫស្សី | 10 | 10 | 50 | 20 | 9 | 9 |
| 0209 | សំឡូត | 7 | 7 | 48 | 14 | 5 | 5 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 0210 | សំពៅលូន | 6 | 6 | 19 | 19 | 3 | 3 |
| 0213 | គាស់ក្រឡ | 6 | 6 | 36 | 36 | 2 | 2 |
| 0214 | រុក្ខគីរី | 5 | 5 | 32 | 32 | 2 | 2 |
| 24 | ខេត្តប៉ៃលិន | 4 | 4 | 27 | 27 | 3 | 3 |
| 2402 | សាលាក្រៅ | **4** | **4** | **27** | **27** | **3** | 3 |
| សុរប | | 126 | 126 | 794 | 487 | 104 | 104 |

កំណត់សម្គាល់:

១. ខេត្តបាត់ដំបង និងប៉ៃលិនៈ អង្គការ រ៉ាឆា នឹងធ្វើការផ្សព្វផ្សាយកញ្ចប់ពត៌មានសម្រាប់ប្រជាពលរដ្ឋគ្រប់សាលាបឋមសិក្សាទាំងអស់នៅក្នុងតំបន់គ្រប់គ្រង ហើយ អង្គការ រ៉ាឆា ជ្រើសរើស សាលាបឋមសិក្សាចំនួន ២ មកធ្វើការដាក់ពិន្ទុដោយប្រជាពលរដ្ឋក្នុងឃុំ។

២. ខេត្តសៀមរាប និងបន្ទាយមានជ័យៈ អង្គការ រ៉ាឆា នឹងធ្វើការផ្សព្វផ្សាយកញ្ចប់ពត៌មានសម្រាប់ប្រជាពលរដ្ឋគ្រប់សាលា បឋមសិក្សាទាំងអស់នៅក្នុងតំបន់គ្រប់គ្រង ហើយ អង្គការ រ៉ាឆា ជ្រើសរើស សាលាបឋមសិក្សាចំនួន ២ មកធ្វើការដាក់ពិន្ទុដោយប្រជាពលរដ្ឋក្នុងឃុំចំពោះឃុំដែលបានអនុវត្តកាលពីឆ្នាំចាស់។ ចំពោះឃុំថ្មី អង្គការ រ៉ាឆា ជ្រើសរើស សាលាបឋមសិក្សាចំនួន ១ មកធ្វើការដាក់ពិន្ទុដោយប្រជាពលរដ្ឋក្នុងឃុំ។

## ខ. ផែនការស្តីពីតំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៧ និង ២០១៨ ដែលកំណត់ក្នុងអនុស្សារណៈយោគយល់ លេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការ រ៉ាឆា

| កូដ GIS | ឈ្មោះខេត្ត | ឈ្មោះស្រុក | ចំនួនឃុំ | ចំនួន មណ្ឌលសុខភាព | ចំនួន សាលាបឋមសិក្សា | អង្គការដៃគូអនុវត្ត | សំគាល់(ឆ្នាំនៃការអនុវត្តក្នុងតំបន់គោលដៅ) |
|---|---|---|---|---|---|---|---|
| | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 9 | 9 | 64 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | អូរជ្រៅ | 6 | 4 | 22 | RACHA | គាំទ្រផ្នែកតម្រូវការ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ម៉ាលៃ | 5 | 5 | 22 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | សៀមរាប | អង្គរជុំ | 7 | 6 | 35 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ប្រាសាទបាគង | 8 | 8 | 41 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | សូត្រនិគម | 10 | 10 | 70 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ស្រីស្នំ | 6 | 5 | 28 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | អង្គរធំ | 4 | 4 | 20 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | បន្ទាយស្រី | 6 | 5 | 30 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ស្វាយលើ | 5 | 3 | 34 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | បាត់ដំបង | ថ្មគោល | 10 | 10 | 46 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | សង្កែ | 10 | 9 | 54 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | បាណន់ | 8 | 6 | 65 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | បវេល | 8 | 8 | 76 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ឯកភ្នំ | 7 | 6 | 39 | RACHA | គាំទ្រផ្នែក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | តម្រូវការ |
| | | ម៉ោងឫស្សី | 9 | 9 | 68 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | សំឡូត | 7 | 5 | 40 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | សំពៅលូន | 6 | 3 | 19 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | គាស់ក្រឡ | 6 | 2 | 38 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | រុក្ខគិរី | 5 | 2 | 33 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | រតនៈមណ្ឌល | 5 | 3 | 46 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | កំរៀង | 6 | 3 | 41 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ភ្នំព្រឹក | 5 | 4 | 30 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | ប៉ៃលិន | សាលាក្រៅ | 4 | 3 | 27 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | កំពង់ចាម | បាធាយ | 12 | 8 | 45 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ចំការលើ | 8 | 9 | 46 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ជើងព្រៃ | 10 | 7 | 38 | RACHA | គាំទ្រផ្នែកតម្រូវការ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | កំពង់សៀម | 15 | 12 | 49 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | កងមាស | 11 | 8 | 43 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | កោះសូទិន | 8 | 7 | 33 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ព្រៃឈរ | 15 | 11 | 58 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ស្រីសន្ធរ | 14 | 9 | 38 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ស្ទឹងត្រង់ | 12 | 11 | 43 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | កំពង់ស្ពឺ | បសេត | 15 | 11 | 41 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | គងពិសី | 13 | 10 | 47 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ឧដុង្គ | 15 | 9 | 56 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ឱរ៉ាល់ | 5 | 2 | 26 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ភ្នំស្រួច | 12 | 6 | 52 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | សំរោងទង | 15 | 9 | 52 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ថ្ពង | 7 | 4 | 27 | RACHA | គាំទ្រផ្នែក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | តម្រូវការ |
| | ពោធិ៍សាត់ | បាកាន | 10 | 10 | 84 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | ភ្នំក្រវ៉ាញ | 7 | 5 | 49 | RACHA | គាំទ្រផ្នែកតម្រូវការ |
| | | វាលវែង | 5 | 5 | 22 | RACHA | គាំទ្រផ្នែកតម្រូវការ |
| **Total** | **7** | **44** | **371** | **285** | **1837** | | |

*<u>បញ្ជាក់៖តារាងផែនការស្ដីពីតំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៧ និង ២០១៨ ខាងលើអាចនឹងមានការផ្លាស់ប្ដូរក្នុងករណីចាំបាច់ ដោយស្របតាមការពិភាក្សា និងឯកភាពរវាងភាគីទាំងពីរ</u>*

## ឧបសម្ព័ន្ធទី២៖

## ទម្រង់មាតិកានៃរបាយការណ៍ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម

១ .សេចក្តីផ្តើម

២ .វឌ្ឍនៈភាពនៃការអនុវត្ត

៣ .បញ្ហាប្រឈម

៤. ស្ថានភាពហិរញ្ញវត្ថុ

៥. សេចក្តីសន្និដ្ឋាន

## ឧបសម្ព័ន្ធទី៣៖

## ផែនការសកម្មភាពរួមរវាង NCDD និងអង្គការ RACHA សម្រាប់ឆ្នាំ២០១៦

| ផែនការសកម្មភាព និងថវិកា រួមគ្នា រវាង គ.ជ.អ.ព និង អង្គការ រ៉ាឆា សម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម ឆ្នាំ ២០១៦ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| លរ | ពិពណ៌នាលទ្ធផល/សកម្មភាពអនុវត្ត | ការប៉ាន់ប្រមាណថវិកា សម្រាប់ឆ្នាំ ២០១៦ | | | | | | | | | | ពេលវេលាអនុវត្ត | សំគាល់ |
| | | ថវិកា គ.ជ.អ.ប | | | | | ថវិកា អង្គការ រ៉ាឆា | | | | | | |
| | | សរុប | បាត់ដំបង | សៀមរាប | បន្ទាយមានជ័យ | ប៉ៃលិន | សរុប | បាត់ដំបង | សៀមរាប | បន្ទាយមានជ័យ | ប៉ៃលិន | | |
| I. ថ្នាក់ខេត្ត | | $19,691 | $9,600 | $4,590 | $5,501 | $0 | $8,050 | $4,685 | $1,335 | $135 | $1,895 | | |
| ១ | សិក្ខាសាលាផ្សព្វផ្សាយថ្នាក់ខេត្តស្តីពីដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ដល់ថ្នាក់ដឹកនាំខេត្ត និងស្រុក (២ថ្ងៃ) | $7,533 | $4,871 | $1,100 | $1,562 | - | $3,000 | $2,000 | | | $1,000 | មករា-កុម្ភៈ | អង្គការ រ៉ាឆា រៀបចំសិក្ខាសាលាផ្សព្វផ្សាយតែ១ថ្ងៃគត់នៅពេលចាប់ផ្តើមគម្រោងនៅខេត្តថ្មី |
| ២ | បណ្តុះបណ្តាលស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមសម្រាប់ផ្នែកផ្តត់ផ្គង់ ការប្រមូលទិន្នន័យ និងបោះពុម្ព បិទផ្សាយលើផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4C) និងប្រព័ន្ធទិន្នន័យតាមដាន និងត្រួតពិនិត្យ ដល់ | $6,711 | $2,771 | $1,807 | $2,133 | - | | | | | | កញ្ញា-តុលា | ក្រុមគ្រូឧទ្ទេសថ្នាក់ខេត្ត (មណ្ឌលអភិវឌ្ឍធនធាន |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គ្រប់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា និងមន្ត្រីថ្នាក់ស្រុក (នាយករដ្ឋបាល ការិយាល័យស្រុកប្រតិបត្តិ និងការិយាល័យអប់រំស្រុក)-ចំពោះToT (៣ថ្ងៃ) | | | | | | | | | | | | |
| ៣ | បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលចំនួន៥ ថ្ងៃ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម (ប្រមូលទិន្នន័យ និងបោះពុម្ព បិទផ្សាយលើផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4C) ប្រព័ន្ធទិន្នន័យតាមដាន និងត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ) មន្ត្រីថ្នាក់ស្រុក និងខេត្ត(នាយករដ្ឋបាល ការិយាល័យស្រុកប្រតិបត្តិ និងការិយាល័យអប់រំស្រុក RACHA staff) | $0 | - | - | $0 | - | $4,420 | $2,550 | $1,020 | | $850 | មីនា-មេសា | អ្នកចូលរួមទាំងនោះនឹងក្លាយជាគ្រូបង្គោលហើយបង្រៀនបន្តដល់ ក្រុមប្រឹក្សាឃុំ មណ្ឌលសុខភាព សាលាបឋមសិក្សា និងអ្នកសម្របសម្រួលគណនេយ្យភាពសង្គម |
| ៤ | ចុះតាមដាន និងត្រួតពិនិត្យការអនុវត្តការងារគណនេយ្យភាពសង្គម | $5,447 | $1,958 | $1,683 | $1,806 | - | $630 | $135.00 | $315.00 | $135 | $45.00 | កុម្ភៈ-ធ្នូ | |
| **II. ថ្នាក់ស្រុក** | | **$59,497** | **$29,497** | **$13,500** | **$16,500** | **0** | **22240** | **7527.87** | **7920** | **4987** | **1803** | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ផ្សព្វផ្សាយស្តីពីផែនការយុទ្ធសាស្ត្រ គណនេយ្យភាពសង្គមដល់គ្រប់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា-(២ថ្ងៃ) | $11,747 | $7,692 | $954 | $3,101 | - | $800 | | $800 | | | មីនា-មេសា | អង្គការ វ៉ាដា រៀបចំសិក្ខាសាលា ផ្សព្វផ្សាយតែ១ថ្ងៃគត់នៅពេលចាប់ផ្តើមគម្រោងនៅស្រុកថ្មី |
| ២ | ចុះប្រមូលទិន្នន័យ និងបោះពុម្ពព័ត៌មានសម្រាប់បិទផ្សាយ Post-On | $11,706 | $3,877 | $4,828 | $3,001 | - | $700 | $150.00 | $350 | $150 | $50 | មេសា-មិថុនា | |
| | បើកវគ្គបណ្តុះបណ្តាលស្តីពី កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងសារសុខភាពគន្លឹះដល់ មន្ត្រីឃុំ មណ្ឌលសុខភាព សាលាបឋមសិក្សា និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ | - | - | - | - | - | $7,960 | $2,879.15 | $2,540 | $1,863 | $677 | មីនា-មេសា | |
| | បើកវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ (ប័ណ្ណដាក់ពិន្ទុសហគមន៍) និងសារសុខភាពគន្លឹះដល់ មន្ត្រីឃុំ មណ្ឌលសុខភាព សាលាបឋមសិក្សា និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ | - | - | - | - | - | $7,960 | $2,879.15 | $2,540 | $1,863 | $677 | មេសា-មិថុនា | |
| ៣ | បណ្តុះបណ្តាលស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមសម្រាប់ផ្នែក | $15,933 | $6,926 | $3,897 | $5,110 | - | | | | | | កញ្ញា-តុលា | ក្រុមគ្រូឧទ្ទេសថ្នាក់ខេត្ត/ស្រុក (ទីប្រឹក្សាស្រុក |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្គត់ផ្គង់ ការប្រមូលទិន្នន័យ និងបោះពុម្ព បិទផ្សាយលើផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4C) និងប្រព័ន្ធទិន្នន័យតាមដាន និងត្រួតពិនិត្យ ដល់គ្រប់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា និងមន្ត្រីថ្នាក់ស្រុក (នាយករដ្ឋបាល ការិយាល័យស្រុកប្រតិបត្តិ និងការិយាល័យអប់រំស្រុក))-(៣ថ្ងៃ) | | | | | | | | | | | | ជនបង្គោលគណនេយ្យភាពសង្គម ការិយាល័យអប់រំ<br>ការិ.ស្រុកប្រតិបត្តិ)ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលក្នុងការផ្សព្វផ្សាយនេះ។<br>បញ្ជាក់៖ ការផ្សព្វផ្សាយនេះនឹងផ្តោតសំខាន់លើទម្រង់ប្រមូលទិន្នន័យសម្រាប់អង្គភាពផ្តល់សេវាទាំងបី (មណ្ឌលសុខភាព ឃុំ និងសាលាបឋមសិក្សា) |
| ៤ | ដំណើរការបិទផ្សាយនិងចុះតាមដានការផ្តល់ព័ត៌មាន ការអភិបាលតាមបែបគាំទ្រ និងត្រួតពិនិត្យការអនុវត្តការងារគណនេយ្យភាពសង្គម (ការផ្សព្វផ្សាយកញ្ចប់ពត៌មានសម្រាប់ | $5,653 | $2,303 | $1,163 | $2,187 | - | $840 | $180.00 | $420.00 | $180 | $60.00 | មេសា-មិថុនា | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រជាពលរដ្ឋ និងការចុះតាមដានការផ្តល់ពត៌មាន ការដាក់ពិន្ទុសហគមន៍ ការប្រជុំរួម ការប្រជុំគណៈកម្មការ JAAP) | | | | | | | | | | | | |
| ៥ | កិច្ចប្រជុំឆ្លុះបញ្ចាំង អំពីដំណើរការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម (លទ្ធផលJAAP និងផែនការបន្ត)-(១ ថ្ងៃ) | $14,458 | $8,699 | $2,658 | $3,101 | - | $3,980 | $1,439.57 | $1,270 | $931 | $339 | ត្រីមាសទី៤ | |
| សរុប | | $79,188 | $39,097 | $18,090 | $22,001 | $0 | $30,290 | $12,213 | $9,255 | $5,122 | $3,698 | | |

សូមបញ្ជាក់ពីការណែនាំពីការគ្រោងថវិកាសម្រាប់ដំណើរការវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម (សកម្មភាពទី២-ក្នុងតារាងភ្ជាប់):

- ចំពោះខេត្តមានស្រុកច្រើន (៤ស្រុកឡើងទៅ) មណ្ឌលអាចពិចារណា/គួរ រៀបចំជា វគ្គToT ដល់ថ្នាក់ស្រុកដោយប្រើថវិកានៅខេត្ត រួចស្រុកនឹងបន្តបណ្តុះបណ្តាលផ្ទាល់ដល់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា ដោយប្រើថវិកាស្រុក។

- ចំពោះខេត្តដែលមានស្រុកតិច (១ ស្រុកទៅ ៣ ស្រុក) មណ្ឌលអាចពិចារណា គួររៀបចំបណ្តុះបណ្តាលផ្ទាល់នៅស្រុកដល់ឃុំមណ្ឌលសុខភាព និងសាលាបឋមសិក្សា ដោយប្រើថវិកាស្រុក ។ ដូចនេះថវិកាខ្ទង់បណ្តុះបណ្តាលថ្នាក់ខេត្ត គ្រោងសម្រាប់តែការចុះបេសកកម្ម ថ្លៃធ្វើដំណើរ (របស់គ្រូឧទ្ទេស) ឯកសារបណ្តុះបណ្តាល និងបោះពុម្ពកញ្ចប់ព័តមានសម្រាប់ប្រជាពលរដ្ឋ (I4Cs)ដើម្បីដំណើរការវគ្គបណ្តុះបណ្តាលប៉ុណ្ណោះ។

- ចំពោះការគ្រោងថវិកាស្រុក សូមមើល sheet បន្ទាប់ស្តីពីការគ្រោងថវិកាស្រុកលម្អិត" Detail district's Act Plan"